(បកប្រែក្រៅផ្លូវការ)

# សេចក្ដីប្រកាសរួមដោយនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និង នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រថៃ អំពីលទ្ធផលនៃកិច្ចប្រជុំរបស់ខ្លួន នៅទីក្រុងកូឡាឡាំពួរ ប្រទេសម៉ាឡេស៊ី

យើងនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និង នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រថៃ នៅចំពោះមុខប្រធានាធិបតីសហរដ្ឋអាមេរិក និងនាយករដ្ឋមន្ត្រីប្រទេសម៉ាឡេស៊ី ជាសាក្សី បានជួបប្រជុំនៅទីក្រុងកូឡាឡាំពួរ ប្រទេសម៉ាឡេស៊ី នាពីថ្ងៃទី២៦ ខែតុលា ឆ្នាំ២០២៥ សូមប្រកាសថា ៖

១. យើងសូមបញ្ជាក់ឡើងវិញ នូវការប្ដេជ្ញាចិត្តដ៏រឹងមាំ ចំពោះសន្តិភាព និងសន្តិសុខរវាងប្រទេសទាំងពីរ ដូចដែលបានប្រកាសនៅទីក្រុងប៉ូត្រាជាយ៉ា ប្រទេសម៉ាឡេស៊ី កាលពីថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២៥ កន្លងទៅ និង សូមបញ្ជាក់ជាថ្មី នូវការប្ដេជ្ញាចិត្ត ដោយមិនប្រើកម្លាំង ឬគំរាមកំហែងតាមរយៈកម្លាំង ដើម្បីដោះស្រាយវិវាទដោយសន្តិវិធី និង គោរពព្រំដែនអន្តរជាតិ (international boundary) និងច្បាប់អន្តរជាតិ (international law) ដើម្បីលើកស្ទួយសន្តិភាព សន្តិសុខ ស្ថេរភាព និងវិបុលភាពនៅក្នុងតំបន់ ផ្អែកលើគោលការណ៍គោរពគ្នាក្នុងភាពចាស់ទុំ ដើម្បីឯករាជ្យ អធិបតេយ្យភាព សមភាព បូរណភាពទឹកដី និង អត្តសញ្ញាណជាតិនៃប្រទេសទាំងពីរ។

២. យើងសូមបញ្ជាក់ឡើងវិញ នូវការប្ដេជ្ញាចិត្តដើម្បីអនុវត្តន៍ និងគោរពកិច្ចព្រមព្រៀងដែលបានសម្រេចដោយភាគីទាំងពីរ នៅក្នុងកិច្ចប្រជុំគណៈកម្មាធិការព្រំដែនទូទៅ (GBC)។

៣. យើងបានចុះហត្ថលេខាលើលក្ខខណ្ឌប្រតិបត្តិ (TOR) ស្ដីពីការបង្កើតក្រុមអ្នកសង្កេតការណ៍អាស៊ាន (AOT) ដែលនឹងមានបុគ្គលិកជំនាញពីបណ្ដាប្រទេសសមាជិកអាស៊ាន ដើម្បីធានាថា ការអនុវត្តន៍កិច្ចព្រមព្រៀងឈប់បាញ់ពេញលេញ និងមានប្រសិទ្ធភាព។ យើងសូមអំពាវនាវប្រទេសជាសមាជិកអាស៊ាន សូមផ្ដល់ការគាំទ្រជាអាទិភាព ដើម្បីធ្វើឲ្យប្រាកដថា ក្រុមនេះ(AOT) អាចសម្រេចគោលដៅបើកការប្រជុំរបស់ខ្លួនដោយជោគជ័យ។

៤. យើងបានព្រមព្រៀងក្នុងការកាត់បន្ថយភាពតានតឹង និងស្ដារទំនុកចិត្តឡើងវិញ ព្រមទាំងថែរក្សាទំនាក់ទំនងល្អប្រកបដោយភាពចាស់ទុំ ជាប្រយោជន៍របស់ព្រះរាជាណាចក្រកម្ពុជា និងព្រះរាជណាចក្រថៃ។ ដើម្បីសម្រេចវត្ថុបំណងនេះ យើងយល់ស្របគ្នាដើម្បីអនុវត្តបទឈប់បាញ់ ឲ្យបានពេញលេញ និងមានប្រសិទ្ធភាព ព្រមទាំងស្ដារសន្តិភាព សន្តិសុខ និងស្ថេរភាពនៅតាមបណ្ដោយព្រំដែន ដូចតទៅ ៖

- អនុវត្តការកាត់បន្ថយយោធា ក្រោមការត្រួតពិនិត្យរបស់ក្រុមសង្កេតការណ៍ AOT រួមទាំងការដកយកអាវុធធុនធ្ងន់ ចេញពីតំបន់ព្រំដែន ឲ្យត្រឡប់ទៅមូលដ្ឋានយោធារៀងៗខ្លួនតាមធម្មតា។ ក្នុងបរិបទនេះ ភាគីទាំងពីរត្រូវរៀបចំចាត់ចែងក្រុមកាងាររៀងៗខ្លួន ដើម្បីពិគ្រោះយោបល់ ឈានទៅរកការបញ្ចប់ការងារ និង ត្រូវអនុវត្តផែនការសកម្មភាពជាជំហានៗ ដែលស្ថិតនៅក្រោមការអង្កេតពិនិត្យ នៃក្រុមអ្នក

សង្កេតការចំពោះកិច្ច ហើយបន្ទាប់មក ក្រុម AOT តែម្តង វាត្រូវបានបង្កើតឡើងស្របតាមលក្ខខណ្ឌប្រតិបត្តិ (TOR)។

- ជៀសវាងការផ្សព្វផ្សាយព័ត៌មានមិនពិត ការចោទប្រកាន់ ការលាភពណ៌ និងវោហាសាស្ត្រញុះញង់នានា បើទោះបីជាតាមបណ្តាញផ្សព្វផ្សាយរបស់រដ្ឋាភិបាលផ្លូវការ ឬមិនផ្លូវការក៏ដោយ ដើម្បីបន្ថយឲ្យបាននូវភាពតានតឹង មតិសាធារណៈអវិជ្ជមាន និងបង្កើតបរិយាកាសប្រកបដោយផ្លែផ្កា សម្រាប់កិច្ចសន្ទនាដោយសន្តិវិធី។
- សូមឯកភាពទាំងស្រុង និងអនុវត្តពេញលេញនូវវិធានការកសាងជំនឿចិត្ត ក្នុងការស្តារ និងថែរក្សាទំនុកចិត្ត ជឿជាក់ប្រកបដោយភាពចាស់ទុំ និងថែរក្សាសន្តិភាពតាមព្រំដែន ដើម្បីដោះស្រាយភាពខុសគ្នាដោយសន្តិវិធី ដោយទឹកចិត្តជាអ្នកជិតខាងល្អ ដោយមិត្តភាព និងសាមគ្គីភាព ហើយនិងធ្វើការងារឆ្ពោះទៅមុខ ដើម្បីស្តារទំនាក់ទំនងការទូត រវាងប្រទេសទាំងពីរ។
- សម្របសម្រួល និងអនុវត្តការដោះគ្រាប់មីនមនុស្សធម៌ ចេញពីតំបន់ព្រំដែន ដែលបានព្រមព្រៀងរួចហើយ គណៈកម្មាធិការព្រំដែនទូទៅ (GBC) ដោយមិនប៉ះពាល់ដល់ការស្ទង់មតិ និងការបោះបង្គោលព្រំដែនរវាងប្រទេសទាំងពីរ ដើម្បីការពារជីវិតជនស៊ីវិល និងលើកស្ទួយការអភិវឌ្ឍសេដ្ឋកិច្ចសង្គម។
- បញ្ជាក់ឡើងវិញពីការប្តេជ្ញាចិត្តរបស់យើង ចំពោះការដោះស្រាយវិវាទ និងការបោះបង្គោលព្រំដែនតាមមធ្យោបាយសន្តិវិធី និងតាមច្បាប់អន្តរជាតិ ចៀសវាងពីការគំរាមកំហែង ឬប្រើប្រាស់កម្លាំង ឬសកម្មភាពញុះញង់នានា និងសូមទទួលស្គាល់គណៈកម្មាធិការព្រំដែនថ្នាក់តំបន់ (RBC) គណៈកម្មាធិការព្រំដែនទូទៅ (GBC) និង គណៈកម្មការព្រំដែនចម្រុះ (JBC) ជាយន្តការទ្វេភាគី ដើម្បីធ្វើការងាររួមគ្នាពាក់ព័ន្ធបញ្ហាព្រំដែន តាមរយៈមធ្យោបាយសន្តិវិធី ស្របតាមអាណត្តិរបស់ពួកគេ ស្របតាមអភិបាលតំបន់ ដើម្បីរៀបចំស្ថានភាពនៅលើដីជាក់ស្តែងដោយសន្តិវិធី រួមទាំងបញ្ហាផ្សេងៗទៀតដែលត្រូវបានចោទប្រកាន់ពីបទរំលោភបំពានទៅវិញទៅមក ស្របតាមលទ្ធផលនៃកិច្ចពិភាក្សា នៅក្នុងគណៈកម្មការ JBC និង ការបញ្ឈប់ឲ្យបានរាល់ការពង្រីកវិសាលភាពវិវាទ ព្រមទាំងការកាត់បន្ថយភាពតានតឹងផងដែរ។

៥. ដើម្បីអនុវត្តវិធានការខាងលើនេះឲ្យមានប្រសិទ្ធភាពទាំងស្រុង ភាគីទាំងពីរ យល់ព្រមបញ្ឈប់រាល់សកម្មភាពបង្កអរិភាពសកម្មណាមួយទៀតហើយ។ ជាងនេះទៀត ដូចជា ការបង្ហាញបំណងប្រាថ្នារបស់ថៃ ត្រូវលើកកម្ពស់ទំនុកចិត្ត និងការជឿជាក់ប្រកបដោយភាពចាស់ទុំ។ ថៃ សន្យាដោះលែងចំណាប់ខ្មាំងសង្គ្រាម ដោយគ្មានបង្អែបង្អង់ឡើយ។

៦. យើងយល់ព្រមពង្រឹងកិច្ចសហប្រតិបត្តិការ ការផ្លាស់ប្តូរព័ត៌មាន និងកិច្ចប្រឹងប្រែងទំនាក់ទំនងជាយុត្តិសាស្ត្រ ព្រមទាំងពង្រឹងការត្រួតពិនិត្យព្រំដែន ដើម្បីបង្ការ និងទប់ស្កាត់បទល្មើសឆ្លងព្រំដែន ដែលនាំឲ្យប៉ះពាល់ដល់ពលរដ្ឋនៃប្រទេសទាំងពីរ និង រីករាលដាលដល់សហគមន៍អន្តរជាតិ។

៧. យើងទទួលស្គាល់ភាពចាំបាច់ ដើម្បីបង្កើតអនាគតភ្លឺស្វាង មិនរំឭកពីជម្លោះអតីតកាលទៀតទេ។ រដ្ឋាភិបាលទាំងពីរ សូមបញ្ជាក់ការប្តេជ្ញាចិត្តជាថ្មី ត្រូវដោះស្រាយវិវាទដោយសន្តិវិធី ដោយគោរពតាមច្បាប់អន្តរជាតិពេញលេញ ព្រមទាំងសន្ធិសញ្ញា និងកិច្ចព្រមព្រៀងមានស្រាប់។ លក្ខខណ្ឌផ្សេងៗទៀត បានបង្កើតឡើងសម្រាប់ប្រទេសជាតិទាំងពីរ ត្រូវសម្លឹងឆ្ពោះទៅមុខ និង ចាប់ផ្តើមកសាងទំនាក់ទំនងជាអ្នកជិតខាង ស្របតាមលិខិតលាយលក្ខណ៍អក្សរ និងស្មារតីរបស់ អង្គការសហប្រជាជាតិ (UN) ហើយនិងគោលការណ៍របស់អាស៊ាន (ASEAN) ស្តីពីការដោះស្រាយជម្លោះដោយសន្តិវិធី ដែលត្រួសត្រាយផ្លូវសម្រាប់ជំពូកថ្មីនៃសន្តិភាព និង កិច្ចសហប្រតិបត្តិការ រវាងប្រទេសទាំងពីរ។

៨. យើងបង្ហាញការជឿជាក់ថា កិច្ចប្រជុំនេះ ដែលមានវត្តមានរបស់លោក **ដូណាល់ ត្រាំ** ប្រធានាធិបតីសហរដ្ឋអាមេរិក និងលោក **អាន់វ៉ា អ៊ីប្រាហ៊ីម** នាយករដ្ឋមន្ត្រីម៉ាឡេស៊ី គឺជាគ្រឹះដ៏រឹងមាំសម្រាប់ការគោរពគ្នាប្រកបដោយភាពចាស់ទុំ និងនាំមកសន្តិភាពនៅក្នុងតំបន់។ យើងសូមកោតសរសើរអស់ពីដួងចិត្ត ចំពោះការចូលរួមចំណែកធ្វើសក្ខីកម្មដ៏មានសារសំខាន់របស់លោកប្រធានាធិបតី **ដូណាល់ ត្រាំ** ដើម្បីជំរុញការស្តារទំនាក់ទំនងទ្វេភាគីប្រកបដោយផ្លែផ្កា រវាងព្រះរាជាណាចក្រកម្ពុជា និង ព្រះរាជាណាចក្រថៃ។

ចុះហត្ថលេខានៅទីក្រុងកូឡាឡាំពួរ ថ្ងៃទី២៦ តុលា ឆ្នាំ២០២៥ លើឯកសារបួនច្បាប់ជាភាសាអង់គ្លេស។

(ហត្ថលេខា)

**ហ៊ុន ម៉ាណែត**
នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

**អនុទីន ចន់វីរៈគុល**
នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រថៃ

**សាក្សី ៖**
**អានវ៉ា អ៊ីប្រាហ៊ីម**
នាយករដ្ឋមន្ត្រីប្រទេសម៉ាឡេស៊ី

**ដូណាល់ ជេ ត្រាំ**
ប្រធានាធិបតីសហរដ្ឋអាមេរិក